# ស្គាល់តែជំលោះ

អ៊ឹម សុធារិទ្ធ

សាកលវិទ្យាល័យអូហៃយ៉ូ (Ohio University)

Email. sothearithim@yahoo.com

ខ្ញុំកើតនៅឆ្នាំ ១៩៧០ ដែលមកដល់ពេលនេះមានអាយុ ៣៣ ឆ្នាំគត់ ហើយភាគច្រើននៃអំឡុងពេល ៣៣ឆ្នាំនេះ ខ្ញុំរស់យ៉ាងលំបាកវេទនាជាមួយម្ដាយដែលជាស្ត្រីមេម៉ាយ ដោយលោកឪពុករបស់ខ្ញុំ បានបាត់ខ្លួនក្នុងសង្គ្រាមរវាងរបបសាធារណរដ្ឋខ្មែរជាមួយចលនាខ្មែរក្រហម ដែលមានយៀកកុងជាជំនួយ ។ ពេលខ្ញុំដឹងក្ដីខ្ញុំតែងសួររកឪពុកខ្ញុំរាល់ថ្ងៃ។ រាល់ពេលដែលខ្ញុំសួររកឪពុកខ្ញុំ ម្ដាយខ្ញុំសម្រក់ទឹកភ្នែក ហើយបានប្រាប់ខ្ញុំថាឪពុកខ្ញុំត្រូវបានទ័ពយៀកកុងចាប់ខ្លួនក្នុងសមរភូមិតាំងគោកតាំងក្រសាំង ខេត្តកំពង់ធំ កាលពីខ្ញុំអាយុទើបតែជាងមួយឆ្នាំ ។ នៅពេលខ្ញុំ ឬមិត្តភក្ដិខ្ញុំធ្វើអ្វីខុសម្ដងៗ ចាស់ៗដែលជាញាតិជិតខាងតែងតែមានប្រសាសន៍ថា កុំប្រកាន់អាពួកក្មេងជំនាន់គ្រាប់ផ្លោង ។

នៅពេលខ្ញុំអាយុប្រាំឆ្នាំ គឺឆ្នាំ ១៩៧៥ ខ្ញុំត្រូវបានជំលៀសអោយទៅនៅខេត្តព្រៃវែង និង បន្ទាប់មកទៅស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ក្នុងជំនាន់ ១៩៧៥-១៩៧៨នេះ ខ្ញុំត្រូវបានបំបែកពីម្ដាយអោយនៅជំរុំកុមារប្រមូលផ្ដុំ ហើយត្រូវបានទទួលរងការវាយធ្វើបាបពីប្រធានកងកុមារ និង បង្ខំអោយធ្វើការជាទំងន់ដូចជា គាស់គល់ឈើ ជីកប្រឡាយ លើកទំនប់ ។ល។ ក្នុងវ័យកុមារភាពអាយុ៦ឆ្នាំ ដោយសារតែការវាយធ្វើបាប ការបង្ខំអោយធ្វើកាងារហួសកំលាំង និង ការនឹកម្ដាយ ធ្វើអោយខ្ញុំទីបំផុតបានធ្លាក់ខ្លួនឈឺជាទំងន់ ហើយត្រូវបានបញ្ជូនទៅដាក់ចោលនៅមន្ទីពេទ្យ ដែលប្រៀបបានទៅនឹងស្ថាននរកនៅកណ្ដាលព្រៃរហោរស្ថាន និង គ្មានគ្រូពេទ្យថែរទាំ ។ គ្មានពាក្យអ្វីដែលយកមកពណ៌នាអោយសក្ដិសមនឹងទុក្ខវេទនា ដែលខ្ញុំ និងប្រជាពលរដ្ឋកម្ពុជាដែលនៅក្នុងប្រទេសកម្ពុជាសម័យនោះបានជួបប្រទះនោះទេ ។ ការលំបាកទាំងនេះ មានតែប្រជាពលរដ្ឋខ្មែរដែលនៅក្នុងប្រទេសខ្មែរនាសម័យនោះប៉ុណ្ណោះ ដែលបានទទួល និង បានស្គាល់រសជាតិ ។ ការគ្រាន់តែបានឮ និង ផ្ទុំខ្លឹន មិនស្មើនឹងការបានភ្លក់រស់ជាតិនោះឡើយ ។ ក្នុងជំនាន់នេះ ខ្ញុំបានបាត់បង់ពូពីរនាក់ទៀត ដោយម្នាក់ត្រូវបានចោទថាជាអ្នកស៊ើបការសំងាត់របស់របបសាធារណរដ្ឋខ្មែរ និង ម្នាក់ទៀតត្រូវបានយកទៅសម្លាប់ដោយគ្មានកំហុស ។ មកដល់ឆ្នាំ ១៩៧៩ ខ្ញុំទើបតែមានអាយុ៩ឆ្នាំប៉ុណ្ណោះ តែខ្ញុំ

បានក្លាយជាក្មេងកំព្រា បានទទួលរង និង ភ្លក់គ្រប់រសជាតិយ៉ាងជូចត់ ពីលទ្ធផលនៃជំលោះរបស់ អ្នកនយោបាយខ្មែរ ។

បន្ទាប់ពីរបបនេះត្រូវបានផ្តួលរំលំ ជំលោះទាស់ទែងគ្នានៅតែមាននៅក្នុងប្រទេសកម្ពុជា រវាងសត្រូវចាស់គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលត្រូវបានពួកលោកខាងលិចចោទប្រកាន់ថា ជារបបលើកបន្តុបដោយវៀតណាម និង ក្រុមឧទាមស្របច្បាប់ដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិដោយ ទោះជាក្រុមឧទ្ទាមនេះគ្មានទឹកដី និង ប្រជាជនស្របច្បាប់ក៏ដោយ ។ មិនត្រឹមតែក្រុមឧទ្ទាមអតីតមេឃាតករប្រល័យជាតិឯងនោះទេ គឺមានក្រុមពីរទៀត ដែលក្រុមទាំងពីរនេះមិនដឹងជានៅក្រហែងមេឃណា កាលពីពេល ដែលប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសបានកំពុងរំពឹងរង់ចាំការសង្គ្រោះពីការសម្លាប់រង្គាលរបស់ខ្មែរក្រហម បានរួមគ្នាជាមួយក្រុមខ្មែរក្រហមប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ជំលោះនេះបានបង្កអោយមានសង្គ្រាមស៊ីវិលអូសបន្លាយរហូតដល់មួយទសវត្សរ៍កន្លះទៀត ។ ក្នុងរយៈពេលជាងមួយទសវត្សរ៍នេះ ប្រទេសកម្ពុជាមិនត្រឹមតែបានជួបប្រទះនូវសង្គ្រាមស៊ីវិលប៉ុណ្ណោះទេ តែថែមទាំងត្រូវបានដាក់ទណ្ឌកម្មសេដ្ឋកិច្ចសព្វបែបយ៉ាងទៀតផង ។

រហូតមកដល់ឆ្នាំ១៩៩៣ គឺជាឆ្នាំដែលប្រជាពលរដ្ឋកម្ពុជាបានទន្ទឹងរង់ចាំ និង រំពឹងថា ជំលោះនយោបាយនៅក្នុងសង្គមកម្ពុជាត្រូវបានបញ្ចប់ ដោយមានការជួយជ្រោមជ្រែងទាំងធនធានមនុស្ស និងថវិកាពីអង្គការសហប្រជាជាតិ ដើម្បីរៀបចំការបោះឆ្នោតដោយសេរី និង យុត្តិធម៌មួយ ។ តែទោះជាយ៉ាងណា ជំលោះទាស់ទែងគ្នាអំពីការចែករំលែកអំណាចនៅតែជៀសមិនផុត រហូតដល់បង្កើតអោយមានសហនាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រី ដែលជាប្រព័ន្ធរដ្ឋាភិបាលចំឡែកគ្មានពីរក្នុងលោក ។ មិនយូរប៉ុន្មានជំលោះនយោបាយបានផ្ទុះឡើងទៀតនៅឆ្នាំ ១៩៩៧ ដែលធ្វើអោយអ្នកវិនិយោគ និង ទេសចរបរទេសមានការភ័យខ្លាចរអារនឹងការប្រកបរបរអាជីវកម្ម និង ទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា និង បង្វែរទិសដៅទៅប្រទេសដ៏ទៃវិញ ។ កត្តានេះ បានធ្វើអោយមានអោនភាពសេដ្ឋកិច្ចជាតិ ។

បន្ទាប់ពីរចនាសម្ព័ន្ធខ្មែរក្រហមត្រូវបានបំផ្លាញទាំងស្រុងនៅឆ្នាំ ១៩៩៨ ដោយរដ្ឋាភិបាលអណត្តិទីពីរនោះ ប្រទេសកម្ពុជាត្រូវបានប្រកាសថា មានសន្តិភាពបរិបូណ៌ពេញលេញ ដោយគ្មានទឹកដីនៃក្រុមឧទ្ទាមទៀតទេ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏នៅមានក្រុមខ្មែរសេរីសរសៃប្រាសាទមួយក្រុមនៅបន្តធ្វើវិទ្ធង្សនានៅក្នុងប្រទេសកម្ពុជា ។ ហើយថ្មីៗនេះ អ្នកនយោបាយអន្ទ្រើស១ជំនាន់ថ្មីនេះមានគំនិតមិនចុះសម្រុងគ្នាក្នុងការចែករំលែកអំណាច ហើយបានទាស់ទែងគ្នាលើមូលហេតុផ្សេង១ ដូចជាការមិនទទួលស្គាល់លទ្ធផល

នៃការបោះឆ្នោតដែលបានរៀបចំដោយស្ថាប័នជាតិស្របច្បាប់ និង មានការអង្កេតពីក្រុមសង្កេតការជាតិ និង អន្តរជាតិ ការមិនអាចធ្វើការជាមួយគ្នា ការសុំចែកអំណាចពាក់កណ្តាល ការសុំអោយមានរដ្ឋាភិបាលត្រីភាគី ការសុំចរចារក្រៅច្បាប់អំពីការបង្កើតរដ្ឋាភិបាល ។ល។ និង ។ល។ ការសុំចរចារសម្របសម្រួលគ្នាក្រៅច្បាប់នេះ គឺជាទំលាប់មិនសូវល្អមួយ ដែលបានក្លាយទៅជាវប្បធម៌ទៅហើយសំរាប់អ្នកនយោបាយខ្មែរ ។ អ្នកនយោបាយខ្មែរ តែងតែអួតថាប្រទេសកម្ពុជា ជាប្រទេសនិតិរដ្ឋ តែមិនដែលយកច្បាប់មកធ្វើជាត្រីយ៍មុខទេ ។ ជាអាថទី បើតាមច្បាប់គណៈបក្សឈ្នះឆ្នោតគឺជាអ្នករៀបចំរដ្ឋាភិបាល តែពេលនេះគណៈបក្សចាញ់ឆ្នោតបែរជាអ្នកទាមទារ និង ដាក់លក្ខខ័ណ្ឌ និង រូបមន្តក្នុងការបង្កើតរដ្ឋាភិបាលទៅវិញ ។ ករណីលើកលែងទោស ក៏ត្រូវបានឃើញកើតមានឡើងជារឿយៗក្នុងសង្គមកម្ពុជានេះដែរ ។ មានករណីជាច្រើនទៀត តែករណីទាំងពីរនេះគឺជាឧទាហរណ៍ ដ៏ច្បាស់ក្រឡែតចំពោះការមិនអនុវត្តច្បាប់របស់ក្រុមអ្នកនយោបាយខ្មែរ ។

ពាក្យថា "*អ្នកនយោបាយ*" ត្រូវបានអោយនិយមន័យក្រៅផ្លូវការដោយប្រជាពលរដ្ឋលោកខាងលិចថា គឺ "*ជាអ្នកកុហកប្រកបដោយវិជ្ជាជីវៈ*" *"A Politician is a Professional Liar"* ហើយពាក្យដដែលនោះដែរ ត្រូវបានអោយនិយមន័យក្រៅផ្លូវការដោយប្រជាពលរដ្ឋខ្មែរសមញ្ញថា "*ជាអ្នកនយោបោក* " ឬ "*អ្នកបោកប្រាស់* " ។ តែនិយមន័យពិតប្រាកដរបស់ពាក្យ "*អ្នកនយោបាយ*" គឺមានន័យថា អ្នកមានអំណាច ឬ អ្នកចង់បានអំណាច នៅក្នុងប្រទេសមួយ ដែលតាមរយៈអំណាចនេះ គាត់អាចសម្រេចចិត្តសំខាន់ៗ ដែលមានប្រសិទ្ធភាព និង ឥទ្ធិពលនៅក្នុងប្រទេសទាំងមូល ។ អ្នកដែលត្រូវបានចាត់ទុកថាជាអ្នកនយោបាយមានសមាជិកព្រឹទ្ធសភា សមាជិកសភា រដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និង ប្រធានាធិបតី ។ល។ ហើយអ្នកនយោបាយទាំងនេះជាធម្មតាជា សមាជិកគណៈបក្សនយោបាយ ។ ដូចនេះសង្គមមួយត្រូវការអ្នកនយោបាយដើម្បីដំណើរការ និង អភិវឌ្ឍសង្គមទាំងមូល ។ តែផ្ទុយទៅវិញ មហន្តរាយដែលកើតមានឡើងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា គឺបណ្តាមកពីអ្នកនយោបាយនេះឯង ។ ជាអាថិ ប្រវត្តិសាស្ត្រកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់ហើយថា ក្រោយសម័យអង្គរ អ្នកដែលមានអំណាចមានទំនាស់នឹងគ្នាក្នុងការចែករំលែក និង ដណ្តើមអំណាច ដែលអ្នកមានអំណាចតិចច្រើនតែបានរត់ទៅពឹងពាក់បរទេសអោយជួយ ។ ពីមួយថ្ងៃទៅមួយថ្ងៃ កម្ពុជាបានបាត់បង់ទាំងឥទ្ធិពលដែលធ្លាប់មាន ទាំងសេដ្ឋកិច្ច ធនធានមនុស្ស ធនធានធម្មជាតិ សម្បត្តិវប្បធម៌ជាតិ និង ទឹកដី ។ ទោះបីដឹងថា ការទីពឹង ប្រទេសដ៏ទៃមិនដែលមានផលចំណេញដល់ប្រទេសជាតិក៏ដោយ ក៏រហូតមកដល់ពេលនេះ អ្នកនយោបាយខ្មែរនៅតែមិនចោលគំនិតដណ្តើមអំណាចគ្នា

ហើយអ្នកនយោបាយមួយចំនួនរត់ឆ្លេឆ្លាពឹងពាក់បរទេសអោយជួយគាំទ្រខ្លួនដដែរ ។ ការពឹងពាក់បរទេសអោយជួយគាំទ្រខ្លួន បានបង្ហាញយ៉ាងច្បាស់ក្រឡែតពីភាពទន់ជ្រាយផ្នែកនយោបាយ និង មិនសូវប្រជាប្រិយ៍ភាពក្នុងចំណោមប្រជាពលរដ្ឋខ្លួន ។ លទ្ធិប្រជាធិបតេយ្យ គឺយកប្រជាពលរដ្ឋជាធំ ។ ដូចនេះកត្តា ដែលមានប្រសិទ្ធភាពបំផុតគឺ ការគាំទ្រពីប្រជាពលរដ្ឋភាគច្រើនរបស់ខ្លួន ។ គ្មានអ្នកណាស្រលាញ់ខ្លួនយើង ជាងខ្លួនយើងនោះទេ គ្មានអ្នកណាស្រលាញ់ក្រុមគ្រួសារយើងជាងសមាជិកក្រុមគ្រួសារយើងនោះទេ ហើយក៏គ្មានអ្នកណាស្រលាញ់ប្រទេសជាតិយើងជាជាងប្រជាជាតិយើងនោះដែរ ។ ដូចនេះ កំលាំងប្រជាធិបតេយ្យ គឺគ្មានអ្នកណាជាជាងប្រជាពលរដ្ឋឯងនោះឡើយ តែមិនមែនបរទេសនោះទេ ។

ក្នុងមួយជីវិតខ្ញុំនេះ ខ្ញុំមិនដែលបានស្គាល់ថាអ្វីទៅដែលសន្តិភាពពិតប្រាកដ តែស្គាល់តែការឈឺចាប់ និង ជំលោះនយោបាយក្នុងសង្គមកម្ពុជា ។ ខ្ញុំតែងតែឮថា ខ្មែរបានធ្លាប់មានភាពល្បីល្បាញ និង ជឿនលឿនបំផុតក្នុងសម័យអង្គរបើប្រៀបធៀបទៅនឹងប្រទេសដ៏ទៃក្នុងសម័យនោះ និង ឮអំពីភាពចំរុងចំរើនក្នុងសម័យក្រោយអាណានិគមបារាំង តែមិនដែលបានស្គាល់រស់ជាតិនៃភាពជឿនលឿននោះឡើយ ។ ចាប់តាំងពីខ្ញុំដឹងក្តីជារឿយៗ ខ្ញុំធ្លាប់តែឮថា កម្ពុជាមានមីនច្រើនជាងគេ មានការសម្លាប់ជាតិឯងច្រើនជាងគេ និង មានបំណុលបរទេសច្រើនជាងគេក្នុងតំបន់ ។ល។ តែមិនដែលឮថា កម្ពុជាមានសុវត្ថិភាពល្អជាងគេ មានសុខមាលភាពប្រសើរជាងគេ និង មានការរីកចំរើនជាងគេក្នុងដំបន់នោះទេ ។ លើសពីនេះទៅទៀត អ្នកនយោបាយខ្មែរមួយចំនួនតែងតែយកការអភិវឌ្ឍប្រទេសកម្ពុជាទៅប្រៀបធៀបជាមួយនឹងសម័យអង្គរ និង សម័យឯករាជ្យគឺក្នុងសម័យសង្គមរាស្ត្រនិយម ដែលការប្រៀបធៀបនេះហាក់ដូចជាហួសសម័យទៅហើយ ។ ពាក្យថា អភិវឌ្ឍ គឺត្រូវសំឡឹងទៅមុខ គឺមិនមែនសំឡឹងត្រឡប់ថយក្រោយនោះឡើយ ។

បើនិយាយពីការអភិវឌ្ឍវិញ កម្ពុជាមិនគួរជួបប្រទះនឹងការលំបាកច្រើននោះទេ ព្រោះថាកម្ពុជាមានលក្ខណៈសម្បត្តិល្អយ៉ាងច្រើនសន្ធឹកសន្ធាប់ បើប្រៀបធៀបប្រទេសមួយចំនួនក្នុងតំបន់ ដូចជាប្រទេសហ្វីលីពីន និង ប្រទេសឥណ្ឌូនេស៊ី ដែលជាប្រជុំកោះ និង ដែលមានជំលោះសាសនា ជាតិសាសន៍ និង និយាយភាសាផ្សេងៗខុសៗគ្នា ពីកោះមួយទៅកោះមួយ ។ ប្រទេសកម្ពុជាមានលក្ខណៈទីតាំងភូមិសាស្ត្រល្អ សម្បត្តិធម្មជាតិអំណោយផល មិនសូវមានគ្រោះធម្មជាតិគួរអោយកត់សំគាល់ មិនមានជំលោះសាសនា និង ពូជសាសន៍ និងមានប្រជាជនតិច ។ តែបញ្ហាដែលអភិវឌ្ឍប្រទេសមិនទៅមុខរយៈពេលជាងបីទសវត្សរ៍មកនេះ គឺដោយសារតែការមិនចុះសម្រុងនៃអ្នកនយោបាយ ដែលជំលោះទាំងនោះបានធ្វើអោយគាំងដំណើរការអភិវឌ្ឍប្រទេសទាំងមូល និង បង្កអោយមានភាពមហន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធជាតិទាំងមូល បណ្តាលអោយមាន

គ្រោះមហន្តរាយធម្មជាតិ ដោយសារការកាប់ព្រៃឈើដោយគ្មានវិធានការច្បាស់លាស់ និង ធ្វើអោយកម្ពុជាក្លាយខ្លួនជាកូនបំណុលបរទេសយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ជាធម្មតាគ្រួសារមួយដែលមេគ្រួសារមានជំលោះក្រុមគ្រួសារនោះគ្មានពេលវេលាគិតពីការរកទទួលទាននោះទេ ហើយក្រុមគ្រួសារទាំងមូលក៏គ្មានសុភមង្គលដែរ ។ ជំលោះអ្នកនយោបាយខ្មែរមិនត្រឹមតែជាឧបសគ្គសំរាប់ការអភិវឌ្ឍសង្គមក្នុងពេលបច្ចុប្បន្នប៉ុណ្ណោះទេ តែថែមទាំងបានជះឥទ្ធិពលដ៏សែនអាក្រក់ និង សន្សល់ទុកបំណុល និង វិវេកទាំងឡាយដល់កូនចៅខ្មែរជំនាន់ក្រោយៗទៀត ។

និយាយអោយខ្លីទៅ មហន្តរាយ និង ទុក្ខវេទនាទាំងឡាយ ដែលកើតមកលើប្រជាពលរដ្ឋ និង សង្គមកម្ពុជាទាំងមូលដូចជា ភាពមេម៉ាយ ក្មេងកំព្រា ជនពិការ អសន្តិសុខសង្គម និង ភាពក្រីក្រ ។ល។ គឺបណ្តាលមកពីជំលោះរបស់អ្នកនយោបាយខ្មែរនេះឯង ។ ដូចនេះល្មមដល់ពេលដែលអ្នកនយោបាយទាំងនេះត្រូវរួបរួមគ្នានិង រួមគ្នាកសាងប្រទេសដោយបំភ្លេចចោលនូវកំហឹង និង គំនុំបុគ្គល ហើយយកប្រយោជជាតិជាធំ។ ប្រជាពលរដ្ឋកម្ពុជាដែលជាម្ចាស់ឆ្នោតកំពុងទីពឹងលើអស់លោកអ្នកនយោបាយខ្មែរដែលបានទទួលសន្លឹកឆ្នោតដើម្បីរួមគ្នាបង្កើតរដ្ឋាភិបាលទៅតាមច្បាប់ដែលបានកំណត់ ។ ការមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតគឺជាគំរូមិនសូវល្អមួយ ហើយការបង្កើតរដ្ឋាភិបាលតាមរយៈការចរចារសម្រុះសម្រួលក្រៅច្បាប់ គឺជាគំរូដ៏សែនអាក្រក់សំរាប់ថ្ងៃអនាគត ដោយហេតុថា អ្នកចាញ់ឆ្នោតលើកក្រោយៗ នឹងយកលេស្ចឹមិនទទួលលទ្ធផលនៃការបោះឆ្នោត ហើយតវ៉ារង់ចាំការចរចារសុំចែករំលែកអំណាចក្រៅច្បាប់ទៀត ។ សង្ឃឹមថារដ្ឋាភិបាលសក្តិសម និង ស្របច្បាប់មួយនឹងត្រូវបង្កើតក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីអោយស្របតាមឆន្ទៈ និង ដើម្បីប្រយោជន៏ប្រជាពលរដ្ឋកម្ពុជាទាំងមូល ។

Sothearith Im
186 Mill St. Apt D-7
Athens, Ohio 45701
USA
Email. sothearithim@yahoo.com
Tel. (740) 594 8524

Your comments if you agree with the above article click here. Your comments if you disagree click here.
Your comments if you are impartial click here.